ព្រះរាជាណាចក្រកម្ពុជា

តុលាការកំពូល　　ជាតិ　សាសនា　ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី　　ខាងតាមប្រជារាស្ត្រខ្មែរ

លេខ : ៤១៩ᵁ　　តុលាការកំពូល

ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥　　បានបើកសវនាការ ជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៦

សាលដីកា　　ដែលមានសមាសភាពដូចខាងក្រោម :

លេខ : ៣៨　　១ - ឯកឧត្តម　ឱិត　មុន្នី　ជាប្រធាន

ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៦　　២ - លោក　វៀល　មួន　ជាចៅក្រមរបាយការណ៍

៣ - លោក　សោម សិរីវឌ្ឍ　ជាចៅក្រម

៤ - លោក　ប៉ែន សារឿន　ជាចៅក្រម

៥ - លោក　ម៉ុង មុន្នីចរិយា　ជាចៅក្រម

លោក　ឡេង　វុធ　ជាក្រឡាបញ្ជី

តំណាងមហាអយ្យការ

ឯកឧត្តម　ជួន ស៊ុនឡេង　អគ្គព្រះរាជអាជ្ញារង

ដើម្បី ជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីការដ្ឋប្បវេណីលេខៈ ១៣៨ "ឈ" ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ នៃសំណុំរឿងរដ្ឋប្បវេណីលេខៈ ៣៨៣ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ។

រវាងដើមចោទឈ្មោះ ចាន់ ម៉ៅ ( ជាចុងបណ្តឹងសាទុក្ខ ) ភេទប្រុស អាយុ៤៥ឆ្នាំ ជាតិខ្មែរ តំណាងដោយមេធាវី សុក ជា មានការិយាល័យផ្ទះលេខៈ ៣៧ A ផ្លូវលេខៈ ៣០០ សង្កាត់អូឡាំពិក ខណ្ឌចំការមន ក្រុងភ្នំពេញ ។

និង ចុងចម្លើយឈ្មោះ លឹម ណារី ( ជាម្ចាស់បណ្តឹងសាទុក្ខ ) ភេទស្រី អាយុ៥៤ឆ្នាំ ជាតិខ្មែរ របររកស៊ីលក់ដូរ មានទីលំនៅ ផ្ទះលេខៈ ៣០៧ ក្រុមទី៦ សង្កាត់ទឹកថ្លា ខណ្ឌឬស្សីកែវ ក្រុងភ្នំពេញ ។

មានមេធាវីលោក ឈឹន សុខា និង ធុយ សុគន្ធ ។

តតិយជនឈ្មោះ ឡូ ហេងហួត ។

មានមេធាវីលោក មិក សាជាណា ។

<u>**កម្មវត្ថុបណ្តឹង:**</u> ប្តឹងសុំឱ្យអនុវត្តតាមកិច្ចសន្យាលក់ដី ។

បានឃើញបណ្តឹងសាទុក្ខលេខៈ ៣៨៤ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៥ របស់ឈ្មោះ លឹម ណារី បានប្តឹងមិនសុខចិត្តនឹងសាលដីការបស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខៈ ៤១៩ᵁ ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី០១-០៤-២០០៥ របស់ដើមចោទឈ្មោះ ចាន់ ម៉ៅ ប្តឹងសុំឱ្យអនុវត្តតាមកិច្ចសន្យា

ទិញ-លក់ដី ចុះថ្ងៃទី៣០-០៦-១៩៩៨ ដោយសំអាងហេតុថា : កាលពីថ្ងៃទី៣០-០៦-១៩៩៨ ឈ្មោះ លឹម ណារី និង ឈ្មោះ ហ្គោ. ដេសៀក បានលក់ដីឱ្យខ្លួនក្នុងតម្លៃ ៤.៣៥ x ១៣m² នូវទំហំដី ១០ហិកតា៥០អា ស្ថិតនៅ មណ្ឌល ៤ សង្កាត់៤ ខណ្ឌមិត្តភាព ក្រុងព្រះសីហនុ ដែលមានបណ្ណ័កម្មសិទ្ធិលេខ :A,៣៥៤. A,355. A,៣៥៦ ចុះថ្ងៃទី ១៨-០២-៩៣ ហើយការទិញ-លក់ នៅពេលនោះបានកំណត់ការប្រគល់ប្រាក់ និង កក់ប្រាក់មាន០៤ដំណាក់កាលគឺ :

- លើកទី១ ចំនួន ១០.០០០$ ថ្ងៃទី៣០-០៦-១៩៩៨
- លើកទី២ ចំនួន ១០% ថ្ងៃទី២៣-០៧-១៩៩៨
- លើកទី៣ ចំនួន ២៥% ថ្ងៃទី២៣-០៨-១៩៩៨
- លើកទី៤ ចំនួនជាការបង្គ្រប់បញ្ចប់ ថ្ងៃទី២៣-០៩-១៩៩៨

ក្រោយពីចុះកិច្ចសន្យារួចហើយខ្លួនបានកក់ប្រាក់មុនចំនួន ១០.០០០$ ហើយនៅថ្ងៃទី២៣-០៧-១៩៩៨ បានប្រគល់ចំនួន១០% ស្មើនឹងទឹកប្រាក់៤៥.០០០$ បន្ទាប់មកឈ្មោះ លឹម ណារី និង ហ្គោ ដេសៀក បានបាត់ដំណឹង ឈឹងមិនដឹងទៅណា ហើយការទំនាក់ទំនងក៏ពុំបាន ពេលខ្លួនទៅរកផ្ទះរបស់ឈ្មោះ លឹម ណារី ឃើញបិទទ្វារ ដោយ ទំនាក់ទំនងជាមួយអ្នកទាំងពីរមិនបាន ហើយក៏មិនឃើញអ្នកទាំងពីរមកយកប្រាក់បន្ថែមទៀត ទើបតែនៅពេលថ្មីៗ នេះស្រាប់តែឃើញឈ្មោះ លឹម ណារី មកធ្វើការផ្ទេរសិទ្ធិដីលក់ទៅឱ្យអ្នកផ្សេងទៅវិញ ។

តាមពាក្យបណ្តឹងសុំចូលជាតតិយជន និង សុំបដិសេធដីកាលើកពាក្យបណ្តឹងចុះថ្ងៃទី២៥-០៧-២០០៥ របស់ លោកមេធាវី មិក សាជាណា តំណាងឱ្យតតិយជនឈ្មោះ ឡូ ហេងហួត ហៅ ឡោ ហួអ៊ុយ បញ្ជាក់ថា :ខ្លួនប្តឹងសុំចូល ជាតតិយជន និង សុំបដិសេធដីកាលើកពាក្យបណ្តឹងដោយសំអាងហេតុថា: កូនក្តីខ្លួនឈ្មោះ ឡូ ហេងហួត បានប្រគល់ ប្រាក់ចំនួន ៤៥.០០០$ ឱ្យទៅឈ្មោះ ចាន់ ម៉ៅ ដើម្បីកក់ដីចំនួន ១០ ហិកតា ដែលមានពណ្ណ័កម្មសិទ្ធិលេខ: A,៣៥៤ A, ៣៥៥ ចុះថ្ងៃទី១៨-០២-១៩៩៣ ។

បន្ទាប់មកឈ្មោះ ចាន់ ម៉ៅ បានយកលុយនេះទៅប្រគល់ឱ្យឈ្មោះ ហ្គោ ដេសៀក និង មានសាក្សីឈ្មោះ លឹម ណារី បានដឹងឮផង ព្រមទាំងមានផ្តិតមេដៃលើកិច្ចសន្យាចុះថ្ងៃទី២៣-០៧-១៩៩៨ ជាភស្តុតាងស្រាប់ ។

លុះក្រោយមកទៀតកូនក្តីខ្លួនឈ្មោះ ឡូ ហេងហួត ហៅ ឡោ ហួអ៊ុយ បានប្រគល់ប្រាក់កក់បន្ថែមចំនួន ៣០.០០០$ ទៀតឱ្យទៅឈ្មោះ ហ្គោ ដេសៀក ហើយឈ្មោះនេះក៏បានចុះហត្ថលេខាទទួលប្រាក់ដូចមានក្នុងកិច្ចសន្យា ដែលបានបកប្រែជាភាសាខ្មែរ និង ភាសាចិន ។ កូនក្តីខ្លួន បានសន្យាប្រគល់ប្រាក់គ្រប់ចំនួននៅថ្ងៃទី១៥-០៩-១៩៩៨ ប៉ុន្តែដល់ថ្ងៃប្រគល់ប្រាក់គ្រប់ចំនួន( ១៥-០៩-១៩៩៨ ) ស្រាប់តែឈ្មោះ ហ្គោ ដេសៀក គេចខ្លួនបាត់តែម្តង ដោយមិនទទួលខុសត្រូវឡើយ ហើយកូនក្តីខ្លួនបានស្វែងរកអាស្រ័យដ្ឋានដែលមានក្នុងកិច្ចសន្យា តែពុំឃើញមាន មនុស្សទេ និង បានទូរស័ព្ទទំនាក់ទំនងឈ្មោះ ហ្គោ ដេសៀក ម្តងថានៅប្រទេសចិន ម្តងថានៅសាំងហ្គាពួរ គឺឈ្មោះ ហ្គោ ដេសៀក មានបំណងអាក្រក់មកលើកូនក្តីខ្លួន ។

ស្រាប់តែក្រោយមកទៀតឈ្មោះ លឹម ណារី មានបំណងធ្វើការផ្ទេរសិទ្ធិដីដែល លក់ឱ្យខ្លួននោះ ទៅឱ្យអ្នក

ផ្សេងទៀតទើបឈ្មោះ ចាន់ ម៉ៅ ដាក់ពាក្យប្តឹងទៅ តុលាការក្រុងព្រះសីហនុ នៅថ្ងៃទី១០-០៤-២០០៥ និង ឈ្មោះ ចាន់ ម៉ៅ បានដាក់ពាក្យសុំឱ្យ តុលាការចេញដីកាសំរេចតាមពាក្យសុំ ហើយតុលាការក៏បានចេញដីកាសំរេចតាមពាក្យសុំលេខ: ៤៣២ត.រ/០២ ហាមឃាត់ការលក់-ដូរ .បញ្ចាំ. ផ្ទេរសិទ្ធិ ឬ ធ្វើអំណោយនូវដីដែលមានលេខ: A₄ ៣៥៤ A₄ ៣៥៥. A₄ ៣៥៦ ចុះថ្ងៃទី១៨-០២-១៩៩៣ ជាបណ្តោះអាសន្នសិន ។ ប៉ុន្តែការសំរេចនោះត្រូវបានលោកមេធាវីតំណាងឱ្យចុងចម្លើយឈ្មោះ លឹម ណារី ប្តឹងជំទាស់ ហើយតុលាការក៏បានសំរេចចេញដីកាកិច្ចការប្រញាប់លេខ: ៣៩២ត.រ/០៥ ចុះថ្ងៃទី១៩-០៥-២០០៥ តម្កល់ដីកាសំរេចតាមពាក្យសុំលេខ: ៤៣២ត.រ/០.២ ចុះថ្ងៃទី០៦-០៤-២០០៥ ទុកជាបានការពេញទាំងមូល ។

ប៉ុន្តែក្រោយពីចេញដីកាសំរេចកិច្ចការប្រញាប់នោះមក តុលាការក្រុងព្រះសីហនុ ក៏បានចេញដីកាលើកពាក្យបណ្តឹងលេខ: ៤១៧ត.រ/០៥ ចុះថ្ងៃទី២៧-០៥-២០០៥ ដោយសំអាងថា : ភាគីដើមបណ្តឹងផ្តល់សិទ្ធិក្នុងការប្តឹងទាមទារដីនោះហើយ ។

បានឃើញ ដីកាសំរេចតាមពាក្យសុំលេខ: ៤៣២ត.រ/០២ ចុះថ្ងៃទី០៦-០៤-២០០៥ របស់ តុលាការក្រុងព្រះសីហនុ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១ - ទទួលពាក្យបណ្តឹងសុំចុះថ្ងៃទី០៥-០៤-២០០៥ របស់លោក ចាន់ ម៉ៅ ទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២ - ហាមឃាត់ការផ្ទេរសិទ្ធិ ការលក់-ដូរ, ការជួល, ការបញ្ចាំ, ការធ្វើអំណោយ នៅលើដីដែលមានបណ្ណ័កម្មសិទ្ធិលេខ: A₄ ៣៥៤/ A₄ ៣៥៥/ A₄ ៣៥៦ ចុះថ្ងៃទី១៨-០២-១៩៩៣ ដែលស្ថិតនៅក្នុងក្រុមទី ភូមិ៤ សង្កាត់៤ ខណ្ឌ័មិត្តភាព ក្រុងព្រះសីហនុ ជាបណ្តោះអាសន្នសិន ដើម្បីរងចំការសំរេចដល់អង្គសេចក្តីពី តុលាការ ។

៣ - ក្នុងការអនុវត្តដីកានេះបើមានភាគីណាមួយមិនសុខចិត្ត ភាគីនោះមានសិទ្ធិប្តឹងមកតុលាការក្រុងព្រះសីហនុវិញ ក្នុងរយះពេល១៥ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលដំណឹងពីដីកានេះ។

បានឃើញពាក្យបណ្តឹងទាស់ចុះថ្ងៃទី២០-០៤-២០០៥ របស់លោកមេធាវី ពុធ ធារី តំណាងឱ្យអ្នកស្រី លឹម ណារី បានប្តឹងទាស់នឹងសេចក្តីសំរេចពីដីកាសំរេចតាមពាក្យសុំទាំងមូល ។

បានឃើញដីកាសំរេចកិច្ចការប្រញាប់លេខ: ៣៩២ ត.រ/០៥ របស់ តុលាការក្រុងព្រះសីហនុ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១ - ទទួលពាក្យបណ្តឹងទាស់របស់លោក ពុធ ធារី មេធាវីតំណាងចុងចម្លើយទុកជាត្រឹមត្រូវតាមទំរង់ និងគតិច្បាប់ ។

២ - តម្កល់ដីកាចារលើពាក្យសុំលេខ: ៤៣២ត.រ/០៥ ចុះថ្ងៃទី០៦-០៤-២០០៥ ទុកជាបានការពេញទាំងមូលដដែល ។

៣ - ដីកាសំរេចកិច្ចការប្រញាប់នេះមានប្រសិទ្ធិភាពអនុវត្តភ្លាម១ ទោះជាមានបណ្តឹងឧទ្ធរណ៍ក៏ដោយ ។

៤ - រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ២.០០០៛០០ គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វ៊ីងចំនួន ១.៨០០៛០០ និង រង្វាន់

ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ២០០៛០០ ប្រាក់នេះបានកាត់យកពីប្រាក់របស់ដើមចោទបានបង់ទុករួចហើយ ។

ដីកាសំរេចកិច្ចការប្រញាប់នេះ ជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូភាគីទុកសិទ្ធិប្តឹងតវ៉ាតាមកំណត់ច្បាប់ ។

បានឃើញ ដីកាលើកពាក្យបណ្តឹងលេខៈ ៤១៧ត.រ/០៥ ចុះថ្ងៃទី២៧-០៥-២០០៥ របស់តុលាការក្រុងព្រះសីហនុ ដែលមានខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

លើកចោលនូវពាក្យបណ្តឹងរបស់ដើមចោទឈ្មោះ ចាន់ ម៉ៅ ចុះថ្ងៃទី០១-០៤-២០០៥ ដោយដើមបណ្តឹងបានផ្តាច់សិទ្ធិក្នុងការប្តឹងទាមទារតាមមាត្រា ២៥ នៃក្រឹត្យ-ច្បាប់លេខៈ ៣៨ក្រ.ច ចុះថ្ងៃទី២៨-១០-១៩៨៨ ស្តីពីកិច្ចសន្យា និង ការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខៈ ៣៦ ចុះថ្ងៃទី៣១-០៥-២០០៥ របស់ឈ្មោះ ចាន់ ម៉ៅ បានប្តឹងមិនសុខចិត្តនឹងដីកាលើកពាក្យបណ្តឹងត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខៈ ១៣៨"ឈ" ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ដែលមាន ខ្លឹមសារនៃសេចក្តីសំរេចដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣១-០៥-២០០៥របស់ឈ្មោះចាន់ ម៉ៅ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ។

២ - បដិសេធដីកាលើកពាក្យបណ្តឹងលេខៈ ៤១៧ត.រ/០៥ ចុះថ្ងៃទី២៧-០៥-២០០៥ របស់តុលាការក្រុងព្រះសីហនុ ចោលជាអសារបង់ ។

៣ - កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០៛០០ គឺ ពន្ធចុះបញ្ជីក្តី និង ពន្ធហ្លឹង ២.៥៥០៛០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤៥០៛០០ ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥.០០០៛០០ និង លើអាជ្ញាធរតុលាការ ៥.០០០៛០០ សរុប ១៣.០០០៛០០ ។

៤ - បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខៈ ៣៨៣ ចុះថ្ងៃទី២៥-០៧-២០០៥របស់សាលាឧទ្ធរណ៍ទៅ តុលាការក្រុងព្រះសីហនុ ដើម្បីចាត់ការដល់អង្គសេចក្តីតាមនីតិវិធី ។

៥ - សាលដីកានេះ ជំនុំជំរះ ជាសាធារណៈ នៅថ្ងៃទី១២-០៨-២០០៥ ចំពោះមុខមេធាវីតំណាងគូក្តី និង មេធាវីតំណាងតតីយជន និង ប្រកាសជាសាធារណៈ នៅថ្ងៃទី២២-០៨-២០០៥ ចំពោះមុខមេធាវីតំណាងតតីយជនកំបាំងមុខមេធាវីតំណាងគូក្តី តែទុកជាចំពោះមុខ ។

បើកផ្លូវប្តឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខៈ ៣៨៤ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៥ របស់ឈ្មោះ លឹម ណារី បានប្តឹងមិនសុខចិត្តនឹងសាលដីកា របស់សាលាឧទ្ធរណ៍ត្រង់ចំណុចនៃសេចក្តីសំរេចទាំងមូល ។

បានឃើញ សារណារបស់ឈ្មោះ លឹម ណារី ចុះថ្ងៃទី១៣ ខែតុលា ឆ្នាំ២០០៥ ។

បានឃើញ សារណាឆ្លើយតបរបស់លោក មិក សាជាណា ជាមេធាវីតំណាងឱ្យឈ្មោះ ឡូ ហេងហួត ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០០៥ ។

បានឃើញ សារណាឆ្លើយតបរបស់លោក ថាន់ ឡេង ជាមេធាវីតំណាងឱ្យឈ្មោះ ចាន់ ម៉ៅ ចុះថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០០៥ ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា :

បណ្តឹងសាទុក្ខរបស់ឈ្មោះ លឹម ណារី ស្ថិតក្នុងកំណត់ច្បាប់ គប្បី លើកយកមកពិចារណា ។

សាលាឧទ្ធរណ៍ សំរេចសេចក្តីមកនេះត្រឹមត្រូវហើយ ។

សូមក្រុមប្រឹក្សា ជំនុំជំរះ សំរេចតាមច្បាប់ ។

ក្រឡាបញ្ជី អានសារណារបស់ឈ្មោះ លឹម ណារី ។

មេធាវីលោក ធុយ សុគន្ធ ការពារឱ្យចុងចម្លើយបានធ្វើសេចក្តីសន្និដ្ឋានថា :

មុនដំបូងខ្លួនសុំឆ្លើយតបនឹងសារណារបស់ ចាន់ ម៉ៅ ដែលលើកឡើងក្នុងសារណាកាលពីថ្ងៃទី៣០-០៦-១៩៩៨ ដែលមានកិច្ចសសន្យារវាង ចាន់ ម៉ៅ និង លឹម ណារី ដែលមានការកក់ប្រាក់ជាបួនដំណាក់កាល គឺ លើកទី១ ចំនួន មួយម៉ឺនដុល្លា លើកទី២ កក់ប្រាក់ជប់ភាគរយ ត្រូវជា បួនម៉ឺនប្រាំពាន់ដុល្លា តែលោក ចាន់ ម៉ៅ មិនបានគោរពកិច្ចសន្យាទេ គឺកក់ប្រាក់បានតែ បីម៉ឺនប្រាំពាន់ដុល្លា តែប៉ុណ្ណោះ ដោយខ្វះ មួយម៉ឺនដុល្លាទៀតគាត់ថា ចាំបង្គ្រប់នៅពេលកក់ប្រាក់លើកទី៣ តែតាំងពីពេលនោះមកបាត់មុខលោក ចាន់ ម៉ៅ រហូតមក ដល់ពេលក្រោយទើបមានឈ្មោះ ឡូ ហេងហួត មកអះអាងថា គាត់ជាអ្នកទិញដីនេះទៅវិញ ហើយលើកឡើងថា អ្នកស្រី លឹម ណារី បានផ្លាស់ទីលំនៅនោះគឺជាការមិនត្រឹមត្រូវឡើយ ។តាមពិតគឺ គាត់ជាអ្នកប្រព្រឹត្តខុសនឹងកិច្ចសន្យាដែលបានព្រមព្រៀងគ្នាមុនទេ។

មេធាវីលោក ឈើន សុខា ការពារឱ្យអ្នកស្រី លឹម ណារី បានធ្វើសេចក្តីសន្និដ្ឋានថា :

នេះជារឿងវិវាទកិច្ចសន្យាការទិញ-លក់ដី និង ជាកាតព្វកិច្ចរបស់គូភាគីតាំងពីរនាក់ ។ មានការកត់ចំណាំដូចខាងក្រោម :

I - មានកិច្ចសន្យាចុះថ្ងៃទី៣០-០៦-១៩៩៨ ធ្វើឡើងរវាងអ្នកស្រី លឹម ណារី ប្តី ហ្គោ ដេសៀក និង ចាន់ ម៉ៅ និង លោក មុំ ថន ដែលមានការផ្តិតមេដៃទទួលស្គាល់ទាំងសងខាង ។ តាមការស្រាវជ្រាវលើសំណុំរឿងមកគឺលោក ចាន់ ម៉ៅ បង្កើតជាកំហុសឡើងដែលមានចំណុចគួរឱ្យសំគាល់ដូចខាងក្រោម :

១/ មិនបានគោរពតាមកិច្ចសន្យាដែលបានព្រមព្រៀងគ្នាទេ ។

២/ ហេតុអ្វីបានជាកម្មសិទ្ធិដែលមិនទាន់បានផ្ទេរសិទ្ធិត្រឹមត្រូវផងគាត់ហ៊ានយកដីនេះទៅលក់ឱ្យលោក ឡូ ហេងហួត ទៅវិញ នេះគឺជាការលួចលក់ដីរបស់អ្នកដទៃ ។

៣/ បើនិយាយអំពីអាជ្ញាយុកាល គឺត្រូវហួសអាជ្ញាយុកាលតាមច្បាប់កំណត់ហើយ ។

II - កិច្ចសន្យាចុះថ្ងៃទី៣០-០៦-១៩៩៨ ការលក់នេះមានកម្មវត្ថុត្រឹមត្រូវជាក់លាក់ ដីនោះមានប្លង់ដល់ទៅបីគឺ $A_1$ ៣៥៤, $A_1$ ៣៥៥, និង $A_1$ ៣៥៦ ដែលមានឈ្មោះនៅក្នុងកម្មសិទ្ធិទាំងអស់បានរួមគ្នាលក់ ហើយបានប្រគល់សិទ្ធិឱ្យអ្នកស្រី លឹម ណារី ធ្វើជាកិច្ចសន្យាដើម្បីលក់ដីទាំងអស់នេះ ដែលមានមេធាវីទទួលស្គាល់ផងដែរ ។

III - កាតព្វកិច្ច កិច្ចសន្យាតាមមាត្រា២២ក្រឹត្យ-ច្បាប់លេខ:៣៨ បញ្ជាក់ថា កិច្ចសន្យាជាច្បាប់របស់គូភាគី

ព្រោះកិច្ចព្រមព្រៀងគ្នាមានការបង់ប្រាក់ជាបួនដំណាក់កាល ទី១ បង់មួយម៉ឺនដុល្លា ទី២ បង់១០%ស្មើ ទឹកប្រាក់ចំនួនបួនម៉ឺនប្រាំពាន់ដុល្លា តែលោក ចាន់ ម៉ៅ បានបង់លើកទី២នេះមិនគោរពតាមកិច្ចសន្យាឡើយ គឺនៅខ្វះ មួយម៉ឺនដុល្លាទៀត លើកទី៣ ២៥% ទៀត តែដោយលើកទី២ ចំពោះប្រាក់ដែលនៅខ្វះគាត់ចាំបង្គ្រាប់ នៅដំណាក់ កាលទី៣ តាំងពី ពេលនោះមកក៏បាត់មុខគាត់រហូត ទើបលេចចេញលោក ឡូ ហេងហួត មកអះអាងថា គាត់ទើបជា អ្នកទិញដីពិតប្រាកដ តែនៅក្នុងកិច្ចសន្យាមិនមានឈ្មោះ ឡូ ហេងហួត ទេ ហេតុអ្វីបានជាគាត់ហ៊ានមកបង់លុយ ជំនួសឈ្មោះ ចាន់ ម៉ៅ ទៅវិញ ? ។

តាមច្បាប់ និង តាមយុត្តិធម៌លោក ឡូ ហេងហួត ត្រូវប្ដឹងលោក ចាន់ ម៉ៅ ទើបជាការត្រឹមត្រូវ ព្រោះលោក ចាន់ ម៉ៅ គាត់យកដីរបស់គេទៅលក់ ហើយបានទទួលប្រាក់ពីលោក ឡូ ហេងហួត ចំណែកកូនក្ដីរបស់ខ្លួនមិនពាក់ពន្ធ័ជាមួយលោក ឡូ ហេងហួត ទេ ។

IV - ការបន្តកិច្ចសន្យាតាមហេតុផលត្រូវផុតអាជ្ញាយុកាលអស់ហើយ ដូចជាមិនបានគោរពតាមកិច្ចសន្យាតាំងពីបង់ប្រាក់កក់នៅដំណាក់កាលទី២មកម្ល៉េះ ។ តាមការប្ដឹងរបស់ភាគីទាំងពីរនោះឃើញថា មានរយៈពេលដល់ទៅប្រាំពីរឆ្នាំ ដូចគ្នា ដូច្នេះកិច្ចសន្យានេះត្រូវបានហួសអាជ្ញាយុកាលដូចគ្នា ។

ការអវត្តមានលោក ហ្គោ ដេសៀក តែប្រពន្ធរបស់គាត់អ្នកស្រី លឹម ណារី មានអាស្រ័យដ្ឋានច្បាស់លាស់ដូច្នេះការលើកពីអវត្តមាននេះ គឺ មិនត្រឹមត្រូវឡើយ ហើយគាត់ថា : បានប្ដឹង P-M ដើម្បីទប់ស្កាត់ការផ្ទេរសិទ្ធិដីធ្លីនេះក៏ជាការមិនត្រឹមត្រូវដែរ ។

ដូច្នេះ សរុបសេចក្ដីមកខ្ញុំសុំបដិសេធ សាលដីការបស់សាលាឧទ្ធរណ៍ចោលទាំងមូល ។ដោយសុំតំកល់ដីកាលើកពាក្យបណ្ដឹង របស់តុលាការក្រុងព្រះសីហនុ ទុកជាបានការវិញ ។

មេធាវីលោក សុក ជា ការពារឱ្យលោក ចាន់ ម៉ៅ បានធ្វើសេចក្ដីសន្និដ្ឋានថា :

កាលពីថ្ងៃទី៣០-០៦-៩៨ កូនក្ដីខ្លួនបានធ្វើកិច្ចសន្យាទិញដីទំហំ ដប់ហិកតាហាសិបអា រវាងអ្នកស្រី លឹម ណារី និង ហ្គោ ដេសៀក ដែលបានសន្យាអនុវត្តជា បួនដំណាក់កាល កូនក្ដីរបស់ខ្លួនបានអនុវត្តត្រឹមត្រូវហើយ នៅថ្ងៃទី២៣-០៧-១៩៩៨ ដោយជូសមុខឱ្យលោក ឡូ ហេងហួត បានប្រគល់ប្រាក់ចំនួន បីម៉ឺនប្រាំពាន់ដុល្លា ឱ្យឈ្មោះ លឹម ណារី និង លោក ហ្គោ ដេសៀក ដោយមានទាំងផ្ដិតមេដៃលើកិច្ចសន្យាទទួលប្រាក់ជាំភស្តុតាងទៀតផង ។

នៅថ្ងៃទី២៦-០៨-៩៨ ដែលត្រូវប្រគល់លុយនៅដំណាក់កាលទី២ឈ្មោះ ឡូ ហេងហួត បានយកប្រាក់ចំនួន បីម៉ឺនដុល្លា ឱ្យទៅឈ្មោះ ហ្គោ ដេសៀក និង លឹម ណារី ដោយផ្ទាល់ព្រមទាំងបានចុះហត្ថលេខាទទួលប្រាក់ទៀតផង លុះដល់ថ្ងៃកំណត់ទី១៥-០៩-៩៨ ជាថ្ងៃប្រគល់ប្រាក់គ្រប់ចំនួនឈ្មោះ លឹម ណារី និង លោក ហ្គោ ដេសៀក បានគេចខ្លួនបាត់មិនព្រមមកអនុវត្តតាមកិច្ចសន្យានេះទេ ។

កូនក្ដីរបស់ខ្លួនបានទៅឃ្លាំមើលដីនោះរហូតខ្លាចមានការផ្ទេរកម្មសិទ្ធិ ដោយខ្លាចទប់ស្កាត់មិនបានកូនក្ដីរបស់ខ្លួនបានប្ដឹងទៅ P-M ដើម្បីជួយទប់ស្កាត់ ។

សំណូមពរ : សុំតំកល់សាលដីការបស់សាលាឧទ្ធរណ៍ទុកជាបានការពេញទាំងមូល ។

មេធាវីលោក មិក សាជាណោ ការពារឱ្យលោក ឡូ ហេងហួត បានធ្វើសេចក្តីសន្និដ្ឋានថា :

លោក ឡូ ហេងហួត បានទិញដីពីលោក ចាន់ ម៉ៅ ដែលមានប្លង់ដីលេខ: A,៣៥៤, A ,៣៥៥ និង A, ៣៥៦ ហើយបានប្រគល់ប្រាក់ចំនួន បួនម៉ឺនប្រាំពាន់ដុល្លារអាមេរិក ឱ្យទៅលោក ចាន់ ម៉ៅ ដោយផ្ទាល់ និង បានកក់ប្រាក់ជាបន្តបន្ទាប់ទៅឱ្យលោក ចាន់ ម៉ៅ សរុប ប្រាំពីរម៉ឺនប្រាំពាន់ដុល្លារអាមេរិក ។ នៅថ្ងៃចុងក្រោយដែលត្រូវបង់បង្គ្រប់ លោក ហ្គោ ដេសៀក ក៏បានគិចខ្លួនរហូតមក ម្តងថានៅចិន ម្តងថានៅសាំងហ្គាពរ៍ នេះសបញ្ជាក់ឱ្យឃើញថា លោក ហ្គោ ដេសៀក មានចេតនាគិចខ្លួនតែម្តង ។ យោងតាមក្រឹត្យ-ច្បាប់លេខ: ៣៨ ក្រច ចុះថ្ងៃទី២៨-១០-៩៨ នៃមាត្រា ២៦ ចែងថា អាជ្ញាយុកាលត្រូវផ្អាកសិន កាលបើភាគីកូនបំណុលអវត្តមានពីលំនៅដ្ឋាន ហើយអវត្តមាននេះត្រូវបានវដ្តអំណាចមូលដ្ឋានបញ្ជាក់ត្រឹមត្រូវតាមច្បាប់ ។ លោក ចាន់ ម៉ៅ និង លឹម ណារី ជាអ្នកត្អូញដេរទេ ពាក្យថា លឹម ណារី ជាអ្នកទទួលសិទ្ធិតាមច្បាប់នោះជាការមិនត្រឹមត្រូវទេគឺគាត់គ្រាន់តែជាសាក្សីប៉ុណ្ណោះ ។

សំណូមពរ : សុំតំកល់សាលដីកាលេខ: ១៣៨ "ឈ" ចុះថ្ងៃទី២២-០៨-២០០៥ របស់ សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ
- ក្រោយពីបានស្តាប់សារណា របស់អ្នកស្រី លឹម ណារី
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីនៃគូភាគី និង តតិយជន
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

យល់ឃើញថា : បណ្តឹងសាទុក្ខលេខ: ៣៨៤ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៥ របស់លោក លឹម ណារី ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមក ជំនុំជំរះ បានដោយយោងតាមមាត្រា១៤ នៃច្បាប់ ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី ។

យល់ឃើញថា : ការដែលមេធាវីចុងចម្លើយលើកឡើងថា ការដែលសាលាឧទ្ធរណ៍សំរេចបដិសេធន៍ដីកាលើកពាក្យបណ្តឹងលេខ: ៤១៧ ត.រ/០៥ ចុះថ្ងៃទី២៧-០៥-២០០៥ របស់តុលាការក្រុងកំពង់សោម ចោលជាអសារបង់ជាការភន្តច្រឡំ ដោយហេតុថា កិច្ចសន្យាចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៨ ហួសអាជ្ញាយុកាល ហើយសុំឱ្យតុលាការកំពូល តំកល់ដីកាលើកពាក្យបណ្តឹង របស់តុលាការក្រុងព្រះសីហនុ នោះជាការពុំត្រឹមត្រូវទេ ព្រោះថាតុលាការក្រុងព្រះសីហនុ បានសំរេចលើកពាក្យបណ្តឹងរបស់ដើមចោទចោលតាមដីកា ដោយមិនបានកោះហៅគូភាគីឱ្យចូលរួមឡើយ ។

យល់ឃើញថា : គូភាគីនៃរឿងក្តីនេះ ពុំបានចូលរួមសវនាការនេះទេ តែមេធាវីរបស់គូភាគីបានចូលរួម ដូចនេះ តុលាការកំពូល ជំនុំជំរះ កំបាំងមុខ ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

យល់ឃើញថា ៖ សាលដីការដ្ឋប្បវេណីលេខៈ ១៣៨"ឈ" ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីកំបាំងមុខដើមចោទ,ចុងចម្លើយ និង តតិយជន ប៉ុន្តែចាត់ទុកជាចំពោះមុខ

១ - ទទួលបណ្តឹងសាទុក្ខលេខៈ ៣៨៤ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៥ របស់អ្នកស្រី លឹម ណារី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២ - តម្កល់សាលដីការដ្ឋប្បវេណីលេខៈ ១៣៨"ឈ" ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣ - បញ្ជូនសំណុំរឿងរដ្ឋប្បវេណីលេខៈ ៤១៩[ក] ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ទៅតុលាការក្រុងព្រះសីហនុ ដើម្បីចាត់ការតាមនីតិវិធី ។

៤ - រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩.០០០៛០០ ដែលចុងចម្លើយ បានបង់គឺ ÷

- ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វ៊ីងចំនួន ៤.០០០៛០០ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០៛០០ សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់,

- ចំណាយលើការប្រគល់ដីកាកោះចំនួន ១៥.០០០៛០០ សរុប ១៩.០០០៛០០ ។

៥ - សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី២៦ ខែមករា ឆ្នាំ២០០៦ ។